ខែឧសភាឆ្នាំ2022

# ចំពោះអ្នកមានអាយុ60ឆ្នាំឡើង អ្នកមានជំងឺមូលដ្ឋាន

## ការចាក់វ៉ាក់សាំងកូវីដ-19
# សេចក្តីជូនដំណឹងអំពីការចាក់លើកទី4

4



**ចាក់ឥតគិតថ្លៃ** ចំណាយសាធារណៈទាំងស្រុង




**អ្នកអាចចាក់វ៉ាក់សាំងលើកទី 4 បាន។**
**អាចទទួលបានប្រសិទ្ធភាពបង្ការការវិវឌ្ឍន៍ធ្ងន់ធ្ងរខ្ពស់ ដោយការចាក់លើកទី4។**

## អ្នកដែលអាចចាក់បាន

យោងតាមចំណេះដឹងផ្នែកវិទ្យាសាស្ត្រដែលទទួលបានបច្ចុប្បន្ន យើងចាប់ផ្តើមការចាក់លើកទី4 នៅអំឡុងចុងខែឧសភាចំពោះបុគ្គលដូចខាងក្រោម។

*អំពីជំងឺមូលដ្ឋាន (មានតែភាសាជប៉ុន)

**ក្នុងចំណោមអ្នកដែលកន្លងបាន 5ខែក្រោយចាក់វ៉ាក់សាំងលើកទី3**

① **អ្នកអាយុ60ឆ្នាំឡើង**

② **អ្នកអាយុ18ឆ្នាំឡើងនិងមានជំងឺមូលដ្ឋាន ក្រៅពីនេះ អ្នកដែលគ្រូពេទ្យទទួលស្គាល់ថាមានហានិភ័យវិវឌ្ឍន៍ធ្ងន់ធ្ងរខ្ពស់**

※ **អ្នកចូលលក្ខខណ្ឌ ①** សូមយកបង្កាន់ដៃចាក់វ៉ាក់សាំងដែលផ្ញើពីអាជ្ញាធរនៃកន្លែងដែលអ្នករស់នៅ ទៅទីតាំងចាក់វ៉ាក់សាំង។

※ **អំពីថាតើចូលលក្ខខណ្ឌ ② ឬទេ**
ចំពោះអ្នកដែលបានទទួលការពិនិត្យដោយស្ថាប័នវេជ្ជសាស្ត្រដោយសារជំងឺមូលដ្ឋានជាដើម និងអ្នកដែលមានស្ថាប័នវេជ្ជសាស្ត្រដែលអាចពិគ្រោះជាមុន សូមពិគ្រោះជាមួយគ្រូពេទ្យនៃគ្រឹះស្ថានវេជ្ជសាស្ត្រនោះ។
ចំពោះអ្នកដែលមិនមានស្ថាប័នវេជ្ជសាស្ត្រដែលអាចពិគ្រោះជាមុនបាន សូមពិគ្រោះពេលត្រួតពិនិត្យវេជ្ជសាស្ត្របឋមនៅទីតាំងចាក់វ៉ាក់សាំង។ គួរបញ្ជាក់ថា របៀបចែកបង្កាន់ដៃចាក់វ៉ាក់សាំង សូមពិនិត្យការផ្តល់ព័ត៌មានពីអាជ្ញាធរនៃកន្លែងដែលអ្នករស់នៅ។

**ចំពោះការចាក់លើកទី4 សម្រាប់អ្នកក្រៅពី①②**
**យើងនឹងប្រមូលព័ត៌មានផ្សេងៗហើយពិចារណាជាបន្តទៅទៀត។**

## វ៉ាក់សាំងដែលប្រើ

ប្រើវ៉ាក់សាំងក្រុមហ៊ុន Pfizer ឬក្រុមហ៊ុន Takeda/Moderna មិនថាបានចាក់វ៉ាក់សាំងប្រភេទអ្វីនៅលើកទី1ដល់ទី3 ឡើយ។

## ប្រសិទ្ធភាព នៃវ៉ាក់សាំងកូវីដ-19

● ក្នុងការស្រាវជ្រាវនៅបរទេស គេបានរាយការណ៍ថា ករណីបានចាក់លើកទី 4 ដោយវ៉ាក់សាំងក្រុមហ៊ុន Pfizer ចំពោះអ្នកមានអាយុ 60ឆ្នាំឡើងដែលកន្លងផុតបាន 4ខែឡើងក្រោយចាក់លើកទី 3 ក្នុងពេលរីករាលដាលវីរុសបំប្លែងថ្មីអូមីក្រុង ទោះបីកន្លងផុត 6សប្តាហ៍ក្រោយចាក់ក៏ដោយ ក៏ប្រសិទ្ធភាពបង្ការការវិវឌ្ឍន៍ធ្ងន់ធ្ងរនៅតែបន្តមានមិនធ្លាក់ចុះ។

ប្រភព៖ Bar-On YM et al. Protection by a Fourth Dose of BNT162b2 against Omicron in Israel. NEJM. 2022.

## សុវត្ថិភាព នៃវ៉ាក់សាំងកូវីដ-19

● ក្នុងការស្រាវជ្រាវនៅបរទេស គេបានរាយការណ៍ថា ត្រឹមថ្ងៃទី21ក្រោយចាក់លើកទី4 មិនមានផលប៉ះពាល់ធ្ងន់ធ្ងរឡើយ។

☐ រោគសញ្ញាលេចចេញត្រឹមថ្ងៃទី21 នៃអ្នកមានអាយុ18ឆ្នាំឡើង

| | |
|---|---|
| 50%ឡើង | ឈឺចាប់ 78.8% |
| 10 - 50% | ល្ហិតល្ហៃ 33.2% ឈឺសាច់ដុំ 24.5% ឈឺក្បាល 21.5% ឡើងរឹង/ហើម 12.0% |
| 1 - 10% | ឈឺសន្លាក់ 8.4% ក្តៅខ្លួន37.5អង្សារឡើង 6.6% ឡើងកូនកណ្តុរ 4.7% កន្ទួលក្រហម/ស្បែកឡើងក្រហម 8.0% បញ្ហាផ្នែកវិញ្ញាណ 1.5% ប្រតិកម្មអាឡែកហ្ស៊ី 1.0% |

(*)កម្មវត្ថុ៖ 274នាក់ (ក្រុមហ៊ុន Pfizer：154នាក់ ក្រុមហ៊ុន Moderna：120នាក់)

ប្រភព៖ Gili Regev-Yochay et al. Efficacy of a Fourth Dose of Covid-19 mRNA Vaccine against Omicron. NEJM. 2022.

## ◎អំពីការចាក់វ៉ាក់សាំងនៅទីតាំងផ្សេងពីកន្លែងដែលមានក្នុងសំបុត្រស្នាក់នៅ (ទីលំនៅចុះបញ្ជី)

・សម្រាប់អ្នកដែលត្រូវចាក់វ៉ាក់សាំងនៅស្ថាប័នវេជ្ជសាស្ត្រឬមណ្ឌលចាស់ជរាដែលខ្លួនកំពុងស្នាក់នៅព្យាបាលឬកំពុងស្នាក់នៅ ➡ សូមពិគ្រោះជាមួយស្ថាប័នវេជ្ជសាស្ត្រឬមណ្ឌលចាស់ជរានោះ។

・សម្រាប់អ្នកដែលត្រូវចាក់វ៉ាក់សាំងនៅស្ថាប័នវេជ្ជសាស្ត្រដែលខ្លួនកំពុងព្យាបាលជំងឺមូលដ្ឋាន ➡ សូមពិគ្រោះជាមួយស្ថាប័នវេជ្ជសាស្ត្រនោះ។

・សម្រាប់អ្នកដែលកន្លែងស្នាក់នៅខុសពីទីលំនៅចុះបញ្ជី ➡ អាចមានករណីដែលអាចចាក់នៅតំបន់ដែលកំពុងស្នាក់នៅជាក់ស្តែងបាន។

សូមពិនិត្យនៅគេហទំព័រឬសាកសួរការិយាល័យពិគ្រោះយោបល់របស់ក្រុងស្រុកខណ្ឌឃុំសង្កាត់ភូមិដែលអ្នកកំពុងស្នាក់នៅជាក់ស្តែង។

## ◎ដើម្បីទទួលការចាក់វ៉ាក់សាំង ចាំបាច់ត្រូវមានការព្រមព្រៀងពីសាមីខ្លួន។

នៅក្នុងការចាក់វ៉ាក់សាំង សូមសម្រេចចិត្តថាចាក់ដោយផ្អែកលើឆន្ទៈសាមីខ្លួនបន្ទាប់ពីបានស្វែងយល់ត្រឹមត្រូវអំពីទាំងប្រសិទ្ធភាពនិងហានិភ័យនៃផលរំខាននៃការចាក់វ៉ាក់សាំងការពារឆ្លង។ មិនមានការចាក់វ៉ាក់សាំងដោយគ្មានការព្រមព្រៀងពីអ្នកទទួលការចាក់ទេ។

ហាមឃាត់ការបង្ខំឲ្យចាក់ឬការប្រព្រឹត្តបែបរើសអើងចំពោះអ្នកដែលមិនបានចាក់ ពីសំណាក់កន្លែងការងារឬអ្នកជុំវិញជាដើម។

## ◎មានប្រព័ន្ធជំនួយចំពោះការរងផលប៉ះពាល់សុខភាពដោយសារការចាក់វ៉ាក់សាំងបង្ការ។

នៅក្នុងការចាក់វ៉ាក់សាំងបង្ការ អាចមានករណីកើតមានផលប៉ះពាល់សុខភាព(កើតជំងឺ ឬបន្សល់នូវពិការភាព)។ វាគឺកម្របំផុតប៉ុន្តែក៏មិនអាចបំបាត់ចោលទាំងស្រុងបានដែរ ហេតុនេះប្រព័ន្ធជំនួយត្រូវបានបង្កើតឡើង។

អំពីបែបបទជាដើមដែលចាំបាច់ដើម្បីដាក់ពាក្យស្នើសុំ សូមប្រឹក្សាជាមួយក្រុងស្រុកខណ្ឌឃុំសង្កាត់ភូមិដែលមានក្នុងសំបុត្រស្នាក់នៅរបស់អ្នក។

**សូមបន្តអនុវត្តវិធានការការពារឆ្លងដូចជាពាក់ម៉ាសជាដើម ទាំងក្រោយចាក់វ៉ាក់សាំងរួច**

វ៉ាក់សាំងការពារមេរោគកូរ៉ូណា ត្រូវបានបញ្ជាក់ថាមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្ការការចេញរោគសញ្ញានៃជំងឺកូវីដ-19 ប៉ុន្តែប្រសិទ្ធភាពនោះគឺមិនមែន 100% នោះទេ។ ម្យ៉ាងទៀត ក៏មានឥទ្ធិពលដោយសារការបំប្លែងរបស់វីរុសផងដែរ។

អាស្រ័យហេតុនេះ សូមលោកអ្នកបន្តអនុវត្តវិធានការការពារឆ្លង។ និយាយដោយជាក់លាក់ សូមអនុវត្តដូចជា ការជៀសវាង "3-Mitsu ("ជិត" ទាំង3) (កន្លែងកកកុញ ការប៉ះពាល់ជិតស្និទ្ធ កន្លែងបិទជិត)" ការពាក់ម៉ាស ការលាងដៃនឹងសាប៊ូឬសម្លាប់មេរោគដោយអាល់កុលសម្លាប់មេរោគម្រាមដៃជាដើម។

**សូមបន្តអនុវត្តវិធានការការពារឆ្លង។**



កន្លែងកកកុញ　ការប៉ះពាល់ជិតស្និទ្ធ　កន្លែងបិទជិត

ជៀសវាង "3-Mitsu ("ជិត" ទាំង3)
(កន្លែងកកកុញ ការប៉ះពាល់ជិតស្និទ្ធ កន្លែងបិទជិត)"

ពាក់ម៉ាស

លាងដៃនឹងសាប៊ូ

សម្លាប់មេរោគដោយអាល់កុលសម្រាប់សម្លាប់មេរោគម្រាមដៃ

ករណីមិនអាចមើលគេហទំព័រនេះបាន សូមប្រឹក្សាជាមួយក្រុងស្រុកខណ្ឌឃុំសង្កាត់ភូមិជាដើមដែលអ្នករស់នៅ។

ចំពោះព័ត៌មានលម្អិតអំពីប្រសិទ្ធភាពនិងសុវត្ថិភាពជាដើមនៃវ៉ាក់សាំងការពារមេរោគកូរ៉ូណា សូមមើលគេហទំព័រក្រសួងសុខាភិបាលការងារនិងសុខុមាលភាព ត្រង់ទំព័រ "អំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា"។

សុខាភិបាលការងារនិងសុខុមាលភាព　វីរុសកូរ៉ូណា　វ៉ាក់សាំង　ស្វែងរក

សាកសួរព័ត៌មានតាមរយៈ: